ធនាគារ អូរៀនថល
Oriental Bank | 东方银行

# លក្ខខណ្ឌសេវាធនាគារអនឡាញ

សេវាធនាគារតាមអ៊ីនធឺណិត និង/ឬ សេវាធនាគារតាមទូរស័ព្ទ ORB ("សេវាធនាគារអនឡាញ") លក្ខខណ្ឌទាំងអស់នេះបង្កើតបានជាកិច្ចព្រមព្រៀងរវាងធនាគារ អូរៀនថល និងអតិថិជន/អ្នកប្រើប្រាស់របស់ធនាគារពាក់ព័ន្ធនឹងការប្រើប្រាស់ សេវាធនាគារអ៊ីនធឺណិត និង/ឬសេវាធនាគារតាមទូរស័ព្ទ ORB ("ធនាគារអនឡាញ") ដែលអនុញ្ញាតឱ្យអតិថិជន/អ្នកប្រើប្រាស់មានសិទ្ធិចូលប្រើ និងប្រើប្រាស់គណនីរបស់ខ្លួនតាម រយៈអេឡិកត្រូនិកនូវសេវាធនាគារ ផលិតផល និងសេវាកម្មផ្សេងៗដែលមាននៅក្នុងសេវាធនាគារអនឡាញរបស់ធនាគារ អូរៀនថល ("ORB")។

សូមកត់សម្គាល់ថា លក្ខខណ្ឌជាលាយលក្ខណ៍អក្សរផ្សេងណាមួយដែលពាក់ព័ន្ធនឹងសេវាកម្មគណនីធនាគារ អូរៀនថល របស់អ្នក នឹងបន្តអនុវត្តដដែល។ ចំពោះកម្រិតនៃលក្ខខណ្ឌដែលមិនមានសង្គតភាពនឹងលក្ខខណ្ឌទាំងនេះ លក្ខខណ្ឌទាំងនេះត្រូវយកមកអនុវត្ត(លុះត្រាតែលក្ខខណ្ឌផ្សេងត្រូវបានបញ្ជាក់យ៉ាងច្បាស់ឱ្យអនុវត្តជំនួសលក្ខខណ្ឌទាំងនេះ)។

អសង្គតភាពនៃភាសាណាមួយ នោះភាសាអង់គ្លេសត្រូវយកមកអនុវត្តចំពោះកម្រិតនៃ អសង្គតភាពនេះ។

## 1. និយមន័យ និងការបកស្រាយ

នៅក្នុងលក្ខខណ្ឌទាំងនេះតាមដែលបរិបទតម្រូវ ពាក្យពេចន៍ខាងក្រោមត្រូវមានអត្ថន័យកំណត់ដូចខាងក្រោម លុះត្រាតែមានកំណត់ផ្សេងពីនេះ៖

**គណនី៖** មានន័យថា គណនីរបស់អ្នក មួយ ឬច្រើនដែលមានជាមួយធនាគារ អូរៀនថល រួមមាន គណនីសន្សំ គណនីចរន្ត គណនីបញ្ញើមានកាលកំណត់ ឬគណនីកម្ចី ជាប្រាក់រៀល និងប្រាក់ដុល្លារ ដែលអាចនឹងត្រូវបង្កើតឡើងពេលមួយទៅពេលមួយនៅតាមសាខាធនាគារ អូរៀនថល។

**លេខសម្គាល់អតិថិជន (CIF)៖** លេខសម្គាល់អត្តសញ្ញាណអតិថិជនមួយដោយឡែកនៅក្នុងប្រព័ន្ធរបស់ធនាគារអូរៀនថល ដែលអ្នកទទួលបានអំឡុងពេលបើកគណនីដំបូងរបស់អ្នកជាមួយធនាគារអូរៀនថល

**ខ្លឹមសារ៖** មានន័យ និងរួមបញ្ចូលព័ត៌មាន រូបភាព លីង សម្លេង ក្រាហ្វិក វីដេអូ សូហ្វវែរ ឬសម្ភារផ្សេងៗ រួមទាំង សម្រង់តម្លៃ ព័ត៌មាន និងទិន្នន័យស្រាវជ្រាវ ដែលមានតាមរយៈសេវាធនាគារអនឡាញរបស់ធនាគារ អូរៀនថល។

**វិញ្ញាបនបត្រប្រាក់បញ្ញើមានកាលកំណត់អេឡិកត្រូនិក៖** ឯកសារអេឡិកត្រូនិកនៃព័ត៌មានលម្អិតអំពីគណនីបញ្ញើមានកាលកំណត់របស់អ្នកជាទម្រង់រូបភាពដែលអាចបើកបានតាមរយៈកម្មវិធី ORB Mobile។

**ជីវមាត្រ៖** ខ្ចៅដៃ ទិន្នន័យផ្ទៃមុខ និងមធ្យោបាយផ្សេងណាមួយដែលក្រុមហ៊ុនផលិតឧបករណ៍ចល័តអនុញ្ញាតឱ្យអ្នកប្រើប្រាស់ផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ខ្លួន សម្រាប់គោលបំណងបើកសោឧបករណ៍ចល័តរបស់ខ្លួននិងចូលប្រើកម្មវិធីជាក់លាក់។

**លេខសម្ងាត់ចូលប្រើ៖** មានន័យថា លំដាប់តួអក្សរយ៉ាងតិច 8 តួ និងយ៉ាងច្រើន 16 តួ (រួមមានលេខ និងអក្សរ ដែលត្រូវមាន អក្សរធំ និង លេខ) ដែលអ្នកប្រើប្រាស់បង្កើតនៅពេលចុះឈ្មោះដំបូង ដែលអនុញ្ញាតឱ្យធនាគារ អូរៀនថល អាចកំណត់អត្តសញ្ញាណអ្នកបានមុនពេលចូលប្រើប្រាស់សេវាធនាគារអនឡាញ អូរៀនថល។

**ឧបករណ៍ចល័ត៖** មានន័យថា ទូរស័ព្ទចល័ត ឬទូរស័ព្ទឆ្លាតវៃដែលប្រើប្រាស់សម្រាប់ចូលប្រើកម្មវិធីតាមទូរស័ព្ទ។

**កម្មវិធីទូរស័ព្ទ៖** មានន័យថាកម្មវិធីដែលត្រូវដំឡើងនៅក្នុងឧបករណ៍ចល័តរបស់អ្នកប្រើ (ទូរស័ព្ទឆ្លាតវៃ) ហើយវាអាចត្រូវបានដំឡើង ឬដោនឡូតដោយអ្នកប្រើប្រាស់ពីកន្លែងលក់កម្មវិធីខាងក្រោមដូចជា App Store ឬ Google Play ឬ Huawei App Gallery។

**បញ្ជីទំនាក់ទំនង៖** អនុញ្ញាតឱ្យអ្នកអាចធ្វើប្រតិបត្តិការទៅកាន់លេខទំនាក់ទំនងដែលបានរក្សាទុកនៅក្នុងទូរស័ព្ទរបស់អ្នក។

**ការជូនដំណឹង៖** មានន័យថា សារ SMS និងការជូនដំណឹងក្នុងកម្មវិធីដែលបានផ្ញើទៅអ្នកក្នុងពេលផ្សេងៗដែលទាក់ទងនឹងប្រតិបត្តិការធនាគារ ការជូនដំណឹងទូទៅដោយធនាគារ អូរៀនថល ឬការជូនដំណឹងមុខងារដោយកម្មវិធីទូរស័ព្ទធនាគារ អូរៀនថល។

**លេខសម្ងាត់ប្រើមួយលើក (OTP)៖** មានន័យថា លេខ/លេខកូដដែលបង្កើតដោយឥតព្រាងទុកដោយប្រព័ន្ធសេវាធនាគារតាមទូរស័ព្ទ អូរៀនថល ហើយផ្ញើតាមសារSMS ដើម្បីចុះឈ្មោះលេខទូរស័ព្ទ នៅពេលអ្នកចុះឈ្មោះជាលើកដំបូងដើម្បីបំពេញប្រតិបត្តិការ។

**ព័ត៌មានផ្ទាល់ខ្លួន៖** មានន័យថា ព័ត៌មានផ្ទាល់ខ្លួនដែលអ្នកប្រើប្រាស់ផ្តល់ទៅឱ្យ ធនាគារ អូរៀនថល។

**លេខកូដ PIN៖** លេខបួនខ្ទង់ដោយឡែកដែលអ្នកប្រើបានបង្កើតឡើងនៅពេលដែលពួកគេចុះឈ្មោះជាលើកដំបូង និងត្រូវបានប្រើដើម្បីបញ្ជាក់ប្រតិបត្តិការណាមួយ។

**ថ្លៃសេវា និងបន្ទុក៖** មានន័យថា ការគិតថ្លៃសេវាណាមួយដែលធនាគារដាក់ចេញសម្រាប់សេវាកម្មណាមួយដែលបានប្រើប្រាស់ ឬប្រតិបត្តិការដែលធ្វើឡើងដោយម្ចាស់គណនី។

**លក្ខខណ្ឌស្តង់ដារ៖** មានន័យថា លក្ខខណ្ឌស្តង់ដារដែលមានស្រាប់ដែលគ្រប់គ្រងគណនី ផលិតផល សេ-វាកម្ម ឬសេវាកម្មផ្សេងៗរបស់ធនាគារ អូរៀលថល ត្រូវបានចូលប្រើប្រាស់ ឬផ្តល់ជូនតាមរយៈ ឬនៅក្នុងសេវាធនាគារអនឡាញ អូរៀនថល។

**របាយការណ៍៖** មានន័យថា របាយការណ៍ធនាគាររួមដែលឆ្លុះបញ្ចាំងពីកំណត់ត្រារបស់ធនាគារ អូរៀនថល សម្រាប់រយៈពេលជាក់លាក់ណាមួយនៃគណនីរបស់អ្នកនៅលើកម្មវិធី ORB Mobile។

**លក្ខខណ្ឌ៖** មានន័យថា លក្ខខណ្ឌទាំងនេះដែលគ្រប់គ្រងការប្រើប្រាស់កម្មវិធី ORB Mobile ទម្រង់លិខិតទទួលស្គាល់ការផ្តល់ជូនរបស់អតិថិជន(រួមទាំងឧបសម្ព័ន្ធណាមួយ)ដែលចេញដោយធនាគារ អូរៀនថល ដល់អតិថិជនពីពេលមួយទៅពេលមួយទាក់ទងនឹង កម្មវិធី ORB Mobile និងនៅពេលដែលអាចអនុវត្តបានលក្ខខណ្ឌស្តង់ដាររួមជាមួយនឹងការផ្លាស់ប្តូរណាមួយដែលបានធ្វើឡើងចំពោះលក្ខខណ្ឌទាំងនេះ ពីពេលមួយ ទៅពេលមួយទៅណាមួយ។

**ប្រតិបត្តិការ៖** មានន័យថា កំណត់ត្រា ឬប្រតិបត្តិការហិរញ្ញវត្ថុណាមួយដែលធ្វើឡើង ឬអនុវត្ត ដំណើរការ ឬធ្វើឱ្យមានប្រសិទ្ធភាពដោយគណនីរបស់អ្នក ឬម្ចាស់គណនីផ្សេងទៀតដែលអះអាងថាជាគណនីផ្ទាល់ខ្លួន។

**របាយការណ៍សង្ខេបប្រតិបត្តិការ៖** បញ្ជីបង្ហាញនូវប្រតិបត្តិការទាំងអស់ដែលបានបញ្ចូល ឬធ្វើឡើងនៅក្នុងគណនីធនាគារ អូរៀនថល ក្នុងរយៈពេលជាក់លាក់មួយ។

**ការផ្ទេរប្រាក់៖** មានន័យថា ការផ្ទេរប្រាក់ដែលធនាគារ អូរៀនថល ជាធនាគារទូទាត់ ឬទទួល ជំនួសឱ្យអតិថិជន ដើម្បីអនុវត្តបញ្ជាការទូទាត់ណាមួយពីអតិថិជនម្នាក់ទៅអតិថិ-ជនផ្សេងទៀត។

"យើង", "យើងខ្ញុំ", និង "របស់យើង"៖ មានន័យថា ធនាគារ អូរៀនថល។

"អ្នក", "របស់អ្នក" និង "របស់លោកអ្នក"៖ មានន័យថា អតិថិជន ឬម្ចាស់គណនីដែលប្រើប្រាស់សេវាធនាគារអនឡាញ អូរៀនថល។

## 2. **ការចុះឈ្មោះ**

ការចូលប្រើប្រាស់ និង/ឬអ្នកប្រើប្រាស់សេវាធនាគារតាមអ៊ីនធឺណិតធនាគារ & សេវាធនាគារតាមទូរស័ព្ទ ORB ("សេវាធនាគារអនឡាញធនាគារ អូរៀនថល")

2.1 អ្នកអាចប្រើលេខសម្គាល់អតិថិជន (CIF) ដែលផ្តល់ដោយធនាគារ អូរៀនថល និងកត្តាកំណត់អត្តសញ្ញាណពាក់ព័ន្ធផ្សេងទៀត ដូចជា លេខទូរស័ព្ទ ដើម្បីចុះឈ្មោះសេវាធនាគារអនឡាញ ORB ស្របតាមនីតិវិធីរបស់យើង ក្នុងគោលបំណងដាក់ស្នើការណែនាំទៅធនាគារ អូរៀនថល ដោយមិនចាំបាច់មកកាន់ធនាគារ។ អ្នកត្រូវតែធានាថា អ្នកនឹងបំពេញកាតព្វកិច្ចរបស់អ្នកនៅក្នុងលក្ខខណ្ឌទាំងនេះ ហើយទទួលខុសត្រូវចំពោះការខកខាន ការធ្វេសប្រហែស ឬការខកខានក្នុងការអនុវត្តតាមកាតព្វកិច្ចទាំងនេះ។

2.2 អ្នកយល់ថា អ្នកត្រូវតែដោនឡូតកម្មវិធី ORB Mobile នៅលើឧបករណ៍ចល័តដែលដំណើរការពីប្រព័ន្ធប្រតិបត្តិការដែលយើងគាំទ្រខណៈដែលសេវាធនាគារតាមអ៊ីនធឺណិតអាចត្រូវបានប្រើនៅលើកម្មវិធីរុករកតាមអ៊ីនធឺណិតណាមួយដែលមានសុវត្ថិភាព។

2.3 កម្មវិធី ORB Mobile តម្រូវឱ្យអ្នកប្រើប្រាស់ប្រើប្រាស់ព័ត៌មានសម្ងាត់សុវត្ថិភាពដែលមានពាក្យសម្ងាត់ដើម្បីចូលប្រើ និងលេខកូដ PIN 4 ខ្ទង់ ដើម្បីផ្ទៀងផ្ទាត់ប្រតិបត្តិការ។ ក្នុងអំឡុងពេលចុះឈ្មោះលើកដំបូងនៅក្នុងកម្មវិធី ORB Mobile អ្នកត្រូវតែបង្កើតពាក្យសម្ងាត់ចូលប្រើ និងលេខកូដ PIN 4 ខ្ទង់។

2.4 នៅពេលការចូលប្រើសេវាធនាគារអនឡាញ ORB បានជោគជ័យ ការណែនាំ និងប្រតិបត្តិការទាំងអស់ដែលបានចេញបន្ទាប់មកគឺជារបស់អ្នក ទោះបីជាការចូលប្រើ ការណែនាំ ឬប្រតិបត្តិការបែបនេះអាចត្រូវបានធ្វើឡើងដោយភាគីទីបី ទោះបីជាមានការអនុញ្ញាត ឬគ្មានការអនុញ្ញាតក៏ដោយ។ អ្នកអះអាង និងធានាបន្ថែមថា ការណែនាំទាំងអស់ដែលបានបញ្ជូនបន្តទៅធនាគារពីពេលមួយទៅពេលមួយតាមរយៈកម្មវិធី ORB Mobile នេះគឺត្រឹមត្រូវ ចេញឱ្យត្រឹមត្រូវ និងចងកាតព្វកិច្ចស្របច្បាប់ចំពោះអ្នក។

2.5 តាមរយៈការចុះឈ្មោះនៅក្នុងសេវាធនាគារអនឡាញ ORB អ្នកត្រូវបានចាត់ទុកថាបានអាន យល់ និងយល់ព្រមឱ្យចងកាតព្វកិច្ចដោយលក្ខខណ្ឌនានា ហើយអ្នកទទួលស្គាល់ និងទទួលយកបន្ថែមទៀតថាហានិភ័យទាំងអស់ដែលជាប់ពាក់ព័ន្ធក្នុងការធ្វើការណែនាំ ឬប្រតិបត្តិការដែលធនាគារទទួលបាន គឺមិនអាចត្រឡប់វិញបានទេនៅពេលដែលបានទទួល បញ្ចប់ ឬពឹងផ្អែកលើធនាគារ ហើយថាធនាគារត្រូវបានអនុញ្ញាតឱ្យអនុវត្តតាមការណែនាំដែលទទួលបានពីកម្មវិធី ORB Mobile ។

2.6 នៅពេលចុះឈ្មោះជោគជ័យ គណនីរបស់អ្នកទាំងអស់ដែលអាចអនុវត្តបានសម្រាប់កម្មវិធី ORB Mobile នៅក្រោម លេខសម្គាល់អតិថិជន (CIF) របស់អ្នកនឹងត្រូវបានបង្ហាញនៅក្នុងកម្មវិធីទូរស័ព្ទរបស់អ្នក ហើយអ្នកនឹងអាចបើក និងរក្សាទុក ប្រសិនបើអ្នកអាចត្រូវបានភ្ជាប់ជាមួយគ្នានៅលើសេវាធនាគារអនឡាញ ORB លុះត្រាតែច្បាប់ហាមឃាត់។

2.7 ម្ចាស់គណនីចម្បងនឹងអាចមើលបានតែគណនីនៅក្នុងលេខសម្គាល់អតិថិជន (CIF) ដូចគ្នា រួមទាំងគណនីរួមដែលបានកំណត់ជាមួយម្ចាស់គណនីផ្សេងទៀត។

2.8 ម្ចាស់គណនីរូបវន្តបុគ្គល និងគណនីដែលត្រូវបានកំណត់សម្រាប់ភ្ជាប់នៅធនាគារ អូរៀនថល។ កម្មវិធីទូរស័ព្ទត្រូវបានប្រើប្រាស់រួមគ្នាជាមួយមនុស្សម្នាក់ ឬច្រើននាក់ ហើយលក្ខខណ្ឌនៃការចុះហត្ថលេខាត្រូវបានចុះឈ្មោះនៅបញ្ជរ អតិថិជនទាំងនេះនឹងត្រូវបានអនុញ្ញាតឱ្យចុះឈ្មោះជាមួយកម្មវិធី ORB Mobile តែប៉ុណ្ណោះ ដែលអតិថិជនទាំងនេះត្រូវបានអនុញ្ញាតឱ្យចាប់ផ្តើមប្រតិបត្តិការពីគណនីទាំងនេះ។ ធនាគារ អូរៀនថល មានសិទ្ធិដាក់កម្រិតការចូលប្រើសេវាកម្មរបស់អ្នក រហូតដល់ម្ចាស់គណនីរួមរបស់អ្នកយល់ព្រមឱ្យអ្នកចូលប្រើសេវាកម្មនេះ។ នៅពេលយល់ព្រមតាមលក្ខខណ្ឌ អ្នកត្រូវស្ថិតនៅក្រោមការកំណត់ការផ្ទេរណាមួយដែលកំណត់ដោយធនាគារ អូរៀនថល និងច្បាប់ជាធរមាន។

## 3. ការផ្តល់សេវាកម្ម

3.1 ពីពេលមួយទៅពេលមួយដោយមាន ឬគ្មានការជូនដំណឹងជាមុន ធនាគារ អូរៀនថល អាចកំណត់ ឬផ្លាស់ប្តូរភាពញឹកញាប់ ឬរបៀបនៃការប្រើប្រាស់សេវាធនាគារអនឡាញ ORB រួមទាំងសេវាកម្ម មុខងារ

ផលិតផល និងបរិក្ខារតាមរយៈសេវាធនាគារអនឡាញ ORB។ ធនាគារ អូរៀនថល អាចនឹងបង្កើតសេវាកម្ម និង/ឬផលិតផលថ្មីដែលមានស្រាប់ បន្ថែម ឬកែលម្អតាមរយៈ ឬក្នុងសេវាធនាគារអនឡាញ ORB នៅពេលណាមួយ។ តាមរយៈការប្រើប្រាស់សេវាកម្ម និង/ឬផលិតផលថ្មី បន្ថែម ឬកែលម្អ និងនៅពេលដែលសេវាកម្ម និង/ឬផលិតផលនោះមានសម្រាប់ប្រើប្រាស់ នោះអ្នកនឹងត្រូវចងកាតព្វកិច្ចដោយលក្ខខណ្ឌជាធរមានដែលគ្រប់គ្រងសេវាកម្ម និង/ឬផលិតផលថ្មីៗ។

3.2 កម្មវិធី ORB Mobile នឹងអាចចូលប្រើបានសម្រាប់តែទូរសព្ទចល័ត និងការតភ្ជាប់ទិន្នន័យដែលបំពេញតាមបទប្បញ្ញត្តិ និងការកំណត់រចនាសម្ព័ន្ធចាំបាច់ ដូចដែលធនាគារបញ្ជាក់ពីពេលមួយទៅពេលមួយ ហើយអ្នកយល់ព្រមធានា និងរក្សាការតភ្ជាប់ទូរស័ព្ទ និងទិន្នន័យដែលបំពេញតម្រូវការទាំងនេះដោយចំណាយផ្ទាល់ខ្លួន។ ខាងក្រោមនេះគឺជាបញ្ជីសេវាកម្មដែលបច្ចុប្បន្នអាចអនុវត្តបាននៅក្នុងសេវាធនាគារអនឡាញ ORB៖

- សាកសួរសមតុល្យគណនី
- របាយការណ៍គណនី
- ផ្ទេរប្រាក់រវាងគណនីផ្ទាល់ខ្លួន
- ផ្ទេរប្រាក់ទៅគណនីធនាគារ អូរៀនថល ផ្សេងទៀត
- ផ្ទេរប្រាក់រវាងធនាគារមួយទៅធនាគារមួយទៀត
- ដាក់/ដកប្រាក់បញ្ញើមានកាលកំណត់
- បញ្ចូលលុយទូរស័ព្ទ
- អត្រាប្តូរប្រាក់
- ការកំណត់របស់អ្នកប្រើប្រាស់ និងទំនាក់ទំនងមកធនាគារ

3.3 បញ្ជីទំនាក់ទំនងទូរស័ព្ទ យើងខ្ញុំនឹងទាញយកព័ត៌មាន ដូចជាលេខទូរស័ព្ទពីក្នុងបញ្ជីទំនាក់ទំនងរបស់លោកអ្នក ជៀសជាងការវាយបញ្ចូលលេខទូរស័ព្ទម្តងមួយលេខៗរាល់ពេលប្រតិបត្តិ។ ក្នុងករណីមិនអនុញ្ញាត លោកអ្នកនៅអាចប្រើប្រាស់សេវាកម្មធនាគារបាន ដោយគ្រាន់តែវាយបញ្ចូលលេខទូរស័ព្ទម្តងមួយលេខៗរាល់ពេលប្រតិបត្តិ។

3.4 ធនាគារអាចជូនដំណឹងអ្នកពីពេលមួយ ទៅពេលមួយ អំពីការផ្លាស់ប្តូរមធ្យោបាយដែលអ្នកគួរចូលប្រើប្រាស់ ឬប្រតិបត្តិការកម្មវិធី ORB Mobile។ អ្នកត្រូវតែគោរពតាមការផ្លាស់ប្តូរទាំងនេះ នៅពេលចូលប្រើប្រាស់ ឬប្រតិបត្តិការកម្មវិធី ORB Mobile។

3.5 គោលការណ៍ណែនាំសម្រាប់អ្នកប្រើប្រាស់ស្តីពីប្រតិបត្តិការកម្មវិធី ORB Mobile មានសម្រាប់អ្នក។ អ្នកអាចអនុវត្តតាមគោលការណ៍ណែនាំសម្រាប់អ្នកប្រើប្រាស់ពាក់ព័ន្ធទាំងអស់ នៅពេលអ្នកចូលប្រើ ឬប្រតិបត្តិការកម្មវិធី ORB Mobile ។

3.6 វិសាលភាពមុខងារនិងដំណើរការកម្មវិធីORB Mobileនិងខុសគ្នាពីសេវាធនាគារផ្សេងៗសម្រាប់បណ្តាញអេឡិកត្រូនិកផ្សេង ហើយធនាគារអាចផ្លាស់ប្តូរពីមួយពេលទៅមួយពេលបាន។ អ្នកទទួលស្គាល់ថា៖

3.5.1 សេវាកម្មមួយចំនួនមិនមានសម្រាប់កម្មវិធី ORB Mobile របស់យើងទេ ហើយអាច ឬមិនអាចមាននាពេលអនាគតផងដែរ និង

3.5.2 សេវាកម្មមួយចំនួនដែលមាននាពេលបច្ចុប្បន្ននៅក្នុងកម្មវិធីORB Mobileអាចត្រូវបញ្ឈប់

3.7 អ្នកទទួលស្គាល់ និងយល់ព្រមថា តាមឆន្ទានុសិទ្ធិឯកតោភាគី និងដាច់ខាតរបស់ខ្លួន និងមិនបាច់ជូនដំណឹង និងពីពេលមួយទៅពេលមួយ ធនាគារអាចបន្ថែម ផ្លាស់ប្តូរ កែប្រែ ព្យួរ ឬដកចេញផ្នែកណាមួយ ឬទាំងអស់របស់កម្មវិធី ORB Mobile ឬដំណើរការ ឬមុខងារណាមួយរបស់កម្មវិធី ដោយមិនបាច់ផ្តល់ហេតុផលណាមួយ ឬទទួលខុសត្រូវណាមួយឡើយ។

## កម្រិតប្រតិបត្តិការ

3.8 ប្រភេទប្រតិបត្តិការ និងកម្រិតប្រតិបត្តិការរបស់សេវាធនាគារអនឡាញ ORB មានដូចខាងក្រោម៖

| ប្រភេទមុខងារ | កម្រិតអតិបរមាក្នុងមួយប្រតិបត្តិការ |
|---|---|
| ផ្ទេរទៅគណនីផ្ទាល់ខ្លួន | ឥតកំណត់ |
| ផ្ទេរទៅគណនីភាគីទី 3 ក្នុងធនាគារ អូរៀនថល | 10,000 ដុល្លារ |
| បញ្ចូលលុយទូរស័ព្ទ | 50 ដុល្លារ |
| ផ្ទេរទៅបាគង | 1,000 ដុល្លារ |
| ផ្ទេរទៅធនាគារក្នុងស្រុក | 10,000 ដុល្លារ |
| ដាក់ប្រាក់បញ្ញើមានកាលកំណត់ | ឥតកំណត់ |

3.9 ប្រតិបត្តិការកម្រិតខាងលើត្រូវធ្វើឡើងតាមថវិកាដែលមាននៅក្នុងគណនីរបស់អ្នក ហើយធនាគារ អូរៀនថល រក្សាសិទ្ធិក្នុងការផ្លាស់ប្តូរកម្រិតនេះដោយជូនដំណឹងដល់អ្នកពីមួយពេលទៅមួយពេល។

### ប្រតិបត្តិការមិនមានការអនុញ្ញាត

3.10 ប្រតិបត្តិការគ្មានការអនុញ្ញាត គឺជាប្រតិបត្តិការមួយ ដែលមិនត្រូវបានអនុញ្ញាតដោយអ្នកប្រើប្រាស់ផ្ទាល់ ឧទាហរណ៍ ប្រតិបត្តិការដែលធ្វើឡើងដោយនរណាម្នាក់ក្រៅពីអ្នក ឬអ្នកប្រើប្រាស់ផ្សេងទៀត ដោយអ្នកមិនដឹង និងគ្មានការយល់ព្រមរបស់អ្នក។ ប្រព័ន្ធរបស់ធនាគារកំណត់ថាជាការទទួលខុសត្រូវរបស់អ្នកចំពោះការខាតបង់ដែលបណ្ដាលមកពីប្រតិបត្តិការដែលគ្មានការអនុញ្ញាត។

### ប្រតិបត្តិការមិនជោគជ័យ

3.11 សំណើសុំប្រតិបត្តិការណាមួយនឹងមិនត្រូវបានដំណើរការទេ ប្រសិនបើព័ត៌មានចាំបាច់ទាំងអស់មិនពេញលេញ និង/ឬព័ត៌មានដែលបានផ្ដល់គឺមិនត្រឹមត្រូវ។ តាមឆន្ទានុសិទ្ធិឯកតោភាគី ធនាគារ អូរៀនថល អាចពន្យាពេលសំណើរបស់អ្នក ឬអាចទាក់ទងម្ចាស់គណនីពីមួយពេលទៅមួយពេលដើម្បីធ្វើការផ្ទៀងផ្ទាត់នូវគោលបំណងប្រតិបត្តិការ និងធ្វើការបញ្ជាក់មុនពេលដំណើរការ។ ធនាគារ អូរៀនថល មិនទទួលខុសត្រូវចំពោះភាពមិនត្រឹមត្រូវណាមួយនៅក្នុងសំណើរបស់ម្ចាស់គណនី ឬអ្នកប្រើប្រាស់ដែលមានការអនុញ្ញាត ឬទទួលខុសត្រូវចំពោះម្ចាស់គណនី ឬអ្នកប្រើប្រាស់ដែលមានការអនុញ្ញាតចំពោះការបាត់បង់ណាមួយដែលកើតឡើងពីភាពមិនត្រឹមត្រូវនៅក្នុងសំណើនោះឡើយ។

## 4. ថ្លៃសេវា និងបន្ទុក

4.1 ថ្លៃសេវា និងបន្ទុកអនុវត្តចំពោះការធ្វើប្រតិបត្តិការរបស់អតិថិជននៅលើកម្មវិធី ORB Mobile ដែលបង្កើតឡើងដោយអតិថិជនក្នុងចំនួនទឹកប្រាក់ និងលក្ខណៈដែលបានជូនដំណឹងដោយធនាគារ អូរៀនថល ជាលាយលក្ខណ៍អក្សរ ហើយធនាគារ អូរៀនថល រក្សាសិទ្ធិបន្ថែមទៀតក្នុងការកែប្រែថ្លៃសេវា និងបន្ទុកនេះនៅពេលណាមួយដោយជូនដំណឹងដល់អ្នកជាមុនអំពីការកែប្រែនេះ។ អ្នកត្រូវបង់ថ្លៃសេវា និងបន្ទុកដែលកំណត់ដោយធនាគារ អូរៀនថល សម្រាប់ការផ្ដល់សេវាកម្មវិធី ORB Mobile ក្នុងចំនួនទឹកប្រាក់ និងលក្ខណៈដែលបានជូនដំណឹងដោយធនាគារ អូរៀនថល ជាលាយលក្ខណ៍អក្សរ។ អតិថិ-ជនក៏អាចទទួលខុសត្រូវចំពោះថ្លៃសេវា ឬបន្ទុកផ្សេងទៀតដែលធនាគារ អូរៀនថល កំណត់សម្រាប់ការណែនាំដែលធ្វើឡើងក្នុង ឬអនុលោមតាមសេវាកម្មរបស់កម្មវិធី ORB Mobile និងដែលត្រូវបង់ឱ្យធនាគារ អូរៀនថល ក្រោមលក្ខខណ្ឌស្តង់ដារ។

4.2 សូមរំលឹកថា ធនាគារ អូរៀនថល មានសិទ្ធិដកប្រាក់ដោយស្វ័យប្រវត្តិពីគណនីរបស់អ្នកសម្រាប់ថ្លៃសេវា និងបន្ទុកទាំងអស់សម្រាប់ការចូលប្រើប្រាស់ និងការប្រើប្រាស់សេវាកម្ម ព្រមទាំងថ្លៃសេវារដ្ឋាភិបាល ពន្ធអាករ និង/ឬពន្ធប្រថាប់ត្រា និងថ្លៃសេវានិងបន្ទុកផ្សេងៗទៀត ដែលត្រូវបង់លើប្រតិបត្តិការដែលអ្នកធ្វើ

ឡើងពីពេលមួយទៅពេលមួយដូចដែលរៀបរាប់នៅទីនេះ។ យើងត្រូវមានកាតព្វកិច្ចជូនដំណឹងដល់អ្នក ឬដើម្បីទទួលបានការយល់ព្រមពីអ្នក មុនពេលយើងធ្វើការដកប្រាក់ណាមួយ។

4.3 ក្នុងករណីដែលសេវាណាមួយ ឬពន្ធផ្សេងទៀតដែលមានលក្ខណៈស្រដៀងគ្នានាពេលនេះ ឬក្រោយមកត្រូវគិតថ្លៃដោយច្បាប់លើការទូទាត់ណាមួយនៅទីនេះ អ្នកត្រូវបង់ពន្ធនោះតាមអត្រាដូចដែលច្បាប់បានកំណត់ពីពេលមួយទៅពេលមួយ បន្ថែមពីលើចំនួនទឹកប្រាក់ទាំងអស់ផ្សេងទៀតដែលត្រូវបង់នៅទីនេះ ឬទាក់ទងនឹងសេវាកម្មនេះ។ ប្រសិនបើច្បាប់តម្រូវឱ្យធនាគារ អូរៀនថល ប្រមូល និងធ្វើការទូទាត់ទាក់ទងនឹងពន្ធទាំងនេះក្នុងនាមអ្នក អ្នកយល់ព្រមទូទាត់សងធនាគារ អូរៀនថល ចំពោះការទូទាត់ដូចគ្នា និង/ឬអនុញ្ញាតឱ្យធនាគារ អូរៀនថល ដកប្រាក់ដោយផ្ទាល់ពីគណនីដែលអ្នកបានកំណត់សម្រាប់ពន្ធបែបនេះណាមួយនោះ។

## 5. ការជូនដំណឹង

5.1 ការជូនដំណឹងតាមសារ SMS ពីធនាគារ អូរៀនថល អាចត្រូវបានផ្ញើ ឬស្នើសុំឱ្យផ្ញើទៅកាន់ឧបករណ៍ចល័តរបស់អ្នក។ ធនាគារ អូរៀនថល មិនទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាតជាលទ្ធផលមកពីបុគ្គលណាម្នាក់ក្រៅពីអ្នកដែលកំពុងចូលប្រើសារ SMS ទាំងនោះ និងខ្លឹមសាររបស់សារទាំងនោះដោយសារការធ្វេសប្រហែសរបស់អ្នក។

5.2 ការជូនដំណឹងនៅក្នុងកម្មវិធី ORB Mobile៖ ធនាគារ អូរៀនថល អាចធ្វើការជូនដំណឹង ឬការផ្តល់សញ្ញាទៅកាន់ទូរស័ព្ទរបស់អ្នកដែលដំឡើងកម្មវិធី ORB Mobile សម្រាប់ប្រតិបត្តិការមួយចំនួន ឬធ្វើការទំនាក់ទំនងផ្សព្វផ្សាយទីផ្សារ ឬសេចក្តីប្រកាសព័ត៌មានមួយចំនួនពីធនាគារ អូរៀនថល។

## 6. កាតព្វកិច្ចសន្តិសុខរបស់អតិថិជន

6.1 អ្នកត្រូវរក្សាទុក និងត្រូវធានាថា អ្នកប្រើប្រាស់នីមួយៗនូវគណនីរបស់អ្នកត្រូវរក្សាការសម្ងាត់ និងធានានូវរាល់ព័ត៌មានកំណត់អត្តសញ្ញាណ និងលេខកូដផ្សេងទៀតដែលចេញដោយធនាគារ អូរៀនថល ឬដោយអាជ្ញាធរបញ្ជាក់វិញ្ញាបនបត្រណាមួយដែលទទួលស្គាល់ដោយធនាគារ អូរៀនថល ដើម្បីអនុ ញ្ញាតឱ្យអ្នកឬអ្នកប្រើប្រាស់នោះអាចចូលប្រើ និង/ឬប្រើប្រាស់ធនាគារ អូរៀនថល។ អ្នកយល់ព្រមថា ព័ត៌មានកំណត់អត្តសញ្ញាណ បង្កើតហត្ថលេខារបស់អ្នកដែលព័ត៌មានកំណត់អត្តសញ្ញាណអាចកំណត់អត្តសញ្ញាណអ្នក និងអ្នកប្រើប្រាស់ណាមួយនូវគណនីរបស់អ្នក។

6.2 អ្នកយល់ព្រមទទួលយក និងទទួលថា អ្នកប្រើប្រាស់ម្នាក់ៗនូវគណនីរបស់អ្នកត្រូវចាត់វិធានការប្រុងប្រយ័ត្នទាំងអស់ដើម្បីការពារព័ត៌មានកំណត់អត្តសញ្ញាណដោយដូចខាងក្រោម៖

6.2.1 មិនបង្ហាញ ឬបណ្តាលឱ្យបង្ហាញដល់នរណាម្នាក់នូវពាក្យសម្ងាត់ លេខកូដ PIN និង/ឬ ព័ត៌មានកំណត់អត្តសញ្ញាណណាមួយ ដែលប្រើប្រាស់ដើម្បីចូលប្រើគណនី របស់អ្នកដើម្បីធ្វើប្រតិបត្តិការណាមួយ។

6.2.2 ប្តូរពាក្យសម្ងាត់ និងលេខកូដ PIN ជាប្រចាំ។

6.2.3 ទន្ទេញព័ត៌មានកំណត់អត្តសញ្ញាណ និងកុំកត់ត្រាព័ត៌មានទាំងនោះ។

6.2.4 ជូនដំណឹងធនាគារ អូរៀនថល ភ្លាមៗ ប្រសិនបើមានការសង្ស័យណាមួយដែលថា ព័ត៌មានកំណត់អត្តសញ្ញាណណាមួយត្រូវបានបង្ហាញដល់ភាគីទីបី ដើម្បីអនុញ្ញាតឱ្យធនាគារអូរៀនថល ទប់ស្កាត់ការប្រើប្រាស់ដោយក្លែងបន្លំ ឬគ្មានការអនុញ្ញាតនូវសេវាធនាគារអនឡាញ ORB និង

6.2.5 ចាកចេញពីសេវាធនាគារតាមទូរស័ព្ទ ឬសេវាធនាគារតាមអ៊ីនធឺណិត ORB នៅពេលដែលអ្នក ឬអ្នកប្រើប្រាស់របស់អ្នកមិនប្រើប្រាស់កុំព្យូទ័ររបស់អ្នក។

6.2.6 ក្នុងករណីដែលទូរស័ព្ទដៃរបស់អ្នកដែលកម្មវិធី និង/ឬលេខកូដសុវត្ថិភាពត្រូវបានដំឡើងត្រូវបានបាត់បង់ លួច ឬជំនួស ឬប្រសិនបើអ្នកមានហេតុផលដើម្បីជឿថានរណាម្នាក់បានចូលប្រើគណនីធនាគាររបស់អ្នកដោយប្រើកម្មវិធី ឬលេខកូដសុវត្ថិភាព អ្នកត្រូវតែជូនដំណឹងជាបន្ទាន់ និងណែនាំធនាគារឱ្យបដិសេធលេខកូដសុវត្ថិភាពជាបន្ទាន់ ហើយធ្វើការស្នើសុំជាថ្មីដើម្បីចុះឈ្មោះសម្រាប់កម្មវិធី ORB Mobile។

6.3 អ្នកត្រូវជូនដំណឹងធនាគារ អូរៀនថល ភ្លាមៗ (និងដាក់បញ្ជូនមកធនាគារ អូរៀនថល នូវការបញ្ជាក់ជាលាយលក្ខណ៍អក្សរអំពីការជូនដំណឹងនេះ) ប្រសិនបើអ្នក៖

6.3.1. ដឹង ឬសង្ស័យថា ព័ត៌មានកំណត់អត្តសញ្ញាណណាមួយត្រូវបានបាត់បង់ ឬមាននរណាម្នាក់ផ្សេងទៀតដឹង ឬត្រូវបានសម្របសម្រួលផ្សេងពីនេះ និង/ឬ

6.3.2. ដឹង ឬសង្ស័យថាមានការចូលប្រើដោយគ្មានការអនុញ្ញាត និង/ឬ ប្រើគណនីរបស់អ្នកតាមរយៈកម្មវិធី ORB Mobile ។

6.4 អ្នកត្រូវតែទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាតទាំងឡាយណាដែលបង្កឡើង ដែលធនាគារ អូ-រៀនថល អាចទទួលរង ឬកើតឡើងចំពោះធនាគារ អូរៀនថល អ្នកខ្លួនឯងផ្ទាល់ ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់អ្នក និង/ឬភាគីទីបីណាមួយ ឬដែលអាចកើតឡើងដោយផ្ទាល់ ឬដោយប្រយោលពីការណែនាំដែលធនាគារ អូរៀនថល ទទួលបាន (ទោះបីជាមានការអនុញ្ញាត ឬអត់) បន្ទាប់ពីព័ត៌មានកំណត់អត្តសញ្ញាណណាមួយ ឬទាំងអស់ត្រូវបានបង្ហាញដល់ភាគីទីបី ឬសម្របសម្រួលផ្សេងទៀត រហូតដល់ធនាគារ អូរៀន

ថល បានចាត់វិធានការចាំបាច់ស្របតាមការអនុវត្តដែលកំពុងមានរបស់ខ្លួន ដើម្បីទប់ស្កាត់នូវការណែនាំណាមួយកុំឱ្យមានប្រសិទ្ធភាពដោយការប្រើប្រាស់ព័ត៌មានកំណត់អត្តសញ្ញាណ។

6.5 នៅពេលដែលធនាគារ អូរៀនថល ត្រូវបានអ្នកជូនដំណឹងអំពីកាលៈទេសៈនៅក្នុងប្រការ 6.2.4 និង/ឬប្រការ 6.2.6 ធនាគារ អូរៀនថល នឹងមានសិទ្ធិចាត់វិធានការណាមួយដែលខ្លួនយល់ថាសមស្រប រួមទាំងសិទ្ធិក្នុងការផ្អាកការចូលប្រើរបស់អ្នក និង/ឬអ្នកប្រើប្រាស់របស់អ្នក និងការប្រើប្រាស់កម្មវិធី ORB Mobile និង/ឬលុបចោលជីវមាត្រណាមួយ ដោយធនាគារ អូរៀនថល មិនមានការទទួលខុសត្រូវណាមួយឡើយ។ អ្នក និងអ្នកប្រើប្រាស់របស់អ្នកអាចត្រូវបានផ្តល់នូវជីវៈមាត្រថ្មីតាមឆន្ទានុសិទ្ធិដាច់ខាតរបស់ធនាគារ អូរៀនថល។ សូមប្រាកដថាមានតែព័ត៌មានកំណត់អត្តសញ្ញាណជីវមាត្ររបស់អ្នកប៉ុណ្ណោះដែលត្រូវបានចុះឈ្មោះនៅលើឧបករណ៍នេះ។ ប្រសិនបើឧបករណ៍នេះត្រូវបានចែករំលែកជាមួយបុគ្គលផ្សេងទៀត។ យើងស្នើឱ្យអ្នកចូលដោយប្រើតែពាក្យសម្ងាត់របស់អ្នកប៉ុណ្ណោះ។ អ្នកអាចផ្លាស់ប្តូរជម្រើសចូលប្រើរបស់អ្នកបានគ្រប់ពេលនៅពេលក្រោយនៅក្នុងការកំណត់។

6.6 តាមឆន្ទានុសិទ្ធិរបស់ខ្លួន ធនាគារ អូរៀនថល នឹងមានសិទ្ធិបិទដំណើរការ ឬបដិសេធការប្រើប្រាស់នូវជីវមាត្រណាមួយ នៅពេលណាមួយដោយមិនបាច់កំណត់ហេតុផលណាមួយ ហើយជូនដំណឹងដល់អ្នក។ តាមឆន្ទានុសិទ្ធិរបស់ខ្លួន ធនគារ អូរៀនថល អាចនឹងបើកដំណើរការឡើងវិញ ឬចេញជាថ្មីម្តងទៀតនូវជីវមាត្រណាមួយដើម្បីឱ្យអ្នកបន្តការចូលប្រើ និង/ឬប្រើកម្មវិធី ORB Mobile របស់អ្នកឡើងវិញ។ រាល់ការចំណាយ និងបន្ទុកដែលកើតឡើងដោយសារធនាគារ អូរៀនថល ចេញ បើកដំណើរការឡើងវិញ ឬចេញជីវមាត្រណាមួយឡើងវិញត្រូវជាបន្ទុករបស់អ្នក។ អ្នកត្រូវតែអនុវត្តតាមវិធានសុវត្ថិភាពផ្សេងទៀតដែលកំណត់ដោយធនាគារ អូរៀនថល មិនថានៅលើគេហទំព័ររបស់យើង ឬកំណត់ក្នុងកិច្ចព្រមព្រៀងណាមួយផ្សេងទៀតជាមួយ ធនាគារ អូរៀនថល ឬត្រូវបានធនាគារ អូរៀនថល ជូនដំណឹងដល់អ្នកតាមមធ្យោបាយផ្សេងណាមួយ។

6.7 អ្នកត្រូវតែធានាបន្ថែមទៀត ដោយការចំណាយផ្ទាល់ខ្លួនរបស់អ្នកថាឧបករណ៍ដែលអ្នកចូលប្រើ និង/ឬប្រើកម្មវិធី ORB Mobile ត្រូវមានកម្មវិធីប្រឆាំងមេរោគ និងប្រឆាំង spyware ចុងក្រោយបង្អស់ ហើយកម្មវិធីទាំងនោះត្រូវបានដំឡើងគ្រប់ពេល និង បានធ្វើបច្ចុប្បន្នភាពជាមួយនឹងគំរូចុងក្រោយបំផុត ដើម្បីការពារការប្រើប្រាស់ដោយគ្មានការអនុញ្ញាត និង/ឬចូលទៅកាន់ប្រតិបត្តិការ គណនី និងគណនីផ្សេងៗតាមរយៈកម្មវិធី ORB Mobile Back ។ អ្នកត្រូវតែអនុវត្តតាមវិធានសុវត្ថិភាពផ្សេងទៀតដែលកំណត់ដោយធនាគារ អូ-រៀនថល មិនថានៅលើគេហទំព័ររបស់យើង ឬកំណត់ក្នុងកិច្ចព្រមព្រៀងណាមួយផ្សេងទៀតជាមួយធនាគារ អូរៀនថល ឬត្រូវបានធនាគារ អូរៀនថល ជូនដំណឹងដល់អ្នកតាមមធ្យោបាយផ្សេងណាមួយ។

6.8 អ្នកត្រូវតែធ្វើបច្ចុប្បន្នភាពភ្លាមៗ និងបន្តធ្វើបច្ចុប្បន្នភាពប្រព័ន្ធប្រតិបត្តិការ និងកម្មវិធីសុវត្ថិភាពសម្រាប់ឧបករណ៍ចល័តរបស់អ្នក នៅពេលក្រុមហ៊ុនផលិតឧបករណ៍ចល័ត ឬអ្នកផ្តល់ប្រព័ន្ធប្រតិបត្តិការឧបករណ៍ចល័តរបស់អ្នកបញ្ចេញមកនោះ។

6.9 មុនពេលអ្នកលក់ ឬឱ្យឧបករណ៍ចល័តរបស់ទៅនរណាម្នាក់ អ្នកត្រូវលុបកម្មវិធី ORB Mobile ជាមុនសិន។

6.10 អ្នកទទួលស្គាល់ថា នឹងទទួលខុសត្រូវនិងត្រូវយកចិត្តទុកដាក់ក្នុងការធានាថា ព័ត៌មានដែលអ្នកផ្តល់តាមរយៈកម្មវិធី ORB Mobile គឺពិត ពេញលេញ ត្រឹមត្រូវ និងទាន់បច្ចុប្បន្នភាព។

## 7. អ៊ីនធឺណិត បណ្តាញ និងក្រុមហ៊ុនផ្តល់សេវាទំនាក់ទំនងបណ្តាញ

7.1 អ្នកយល់ថារាល់ការចូលប្រើ និង/ឬការប្រើប្រាស់សេវាធនាគារអនឡាញ ORB នឹងអាចធ្វើទៅបានតាមរយៈអ្នកផ្តល់សេវាអ៊ីនធឺណិតដែលពាក់ព័ន្ធ អ្នកផ្តល់សេវាបណ្តាញ ឬអ្នកផ្តល់បណ្តាញទំនាក់ទំនងនៅក្នុងប្រទេសដែលសេវានេះត្រូវបានចូលប្រើ ហើយចំពោះវិសាលភាពនេះ ការចូលប្រើ និង/ឬប្រើប្រាស់ ORB Mobile Back ត្រូវអនុលោមតាម និងគ្រប់គ្រងដោយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនៃប្រទេសនោះ និងលក្ខខណ្ឌនានាដែលកំណត់ដោយអ្នកផ្តល់សេវាអ៊ីនធឺណិត អ្នកផ្តល់សេវាបណ្តាញ ឬអ្នកផ្តល់បណ្តាញទំនាក់ទំនងដែលពាក់ព័ន្ធ។

7.2 ធនាគារ អូរៀនថល មិនធានាសុវត្ថិភាព និងភាពសម្ងាត់នៃការណែនាំ និងព័ត៌មានផ្សេងទៀត ដែលបានបញ្ជូនតាមរយៈ អ្នកផ្តល់សេវាអ៊ីនធឺណិត អ្នកផ្តល់សេវាបណ្តាញ ឬ អ្នកផ្តល់បណ្តាញទំនាក់ទំនងឬប្រព័ន្ធសមមូលណាមួយនៅក្នុងយុត្តាធិការណាមួយតាមរយៈសេវាធនាគារអនឡាញ ORB ហើយធនាគារ អូ-រៀនថល នឹងមិនទទួលខុសត្រូវចំពោះការចូលប្រើប្រាស់ដោយគ្មានការអនុញ្ញាត ការលួចព័ត៌មាន ឬការបាត់បង់ ឬការខូចខាតណាមួយដែលកើតឡើងការប្រើប្រាស់ណាមួយឡើយ។ លើសពីនេះ អ្នកទទួលយក និងយល់ព្រមថា ធនាគារ អូរៀនថល នឹងមិនទទួលខុសត្រូវចំពោះការខូចផ្នែកអេឡិចត្រូនិច មេកា-និច ទិន្នន័យ ឬការខូច មេរោគកុំព្យូទ័រ កំហុស ឬបញ្ហាពាក់ព័ន្ធដែលអាចបណ្តាលមកពីសេវាកម្មដែលផ្តល់ដោយ អ្នកផ្តល់សេវាអ៊ីនធឺណិត អ្នកផ្តល់សេវាបណ្តាញ ឬ អ្នកផ្តល់បណ្តាញទំនាក់ទំនងដែលពាក់ព័ន្ធណាមួយ។

## 8. ការទទួលខុសត្រូវរបស់ធនាគារ អូរៀនថល

8.1 ធនាគារ អូរៀនថល នឹងទទួលខុសត្រូវចំពោះការខាតបង់ជាក់ស្តែងដែលកើតឡើងចំពោះអតិថិជនដោយសារការក្លែងបន្លំ ឬ ការធ្វេសប្រហែសរបស់បុគ្គលិករបស់ធនាគារ អូរៀនថល។

## 9. ភាពជាម្ចាស់នៃសិទ្ធិកម្មសិទ្ធិបញ្ញា

9.1 ធនាគារ អូរៀនថល (ឬអ្នកទទួលសិទ្ធិរបស់ខ្លួន) ជាម្ចាស់កម្មសិទ្ធិទាំងស្រុង និងអះអាងពីថា ឥឡូវនេះ ឬនៅពេលអនាគត កម្មសិទ្ធិបញ្ញាដែលបានចុះបញ្ជី និងមិនបានចុះបញ្ជី ឬកម្មសិទ្ធិបញ្ញាទាំងអស់ (រួមទាំងពាណិជ្ជសញ្ញា សិទ្ធិថតចម្លង សិទ្ធិសីលធម៌ សិទ្ធិប៉ាតង់ និងសិទ្ធិរចនា) នៅក្នុងប្រព័ន្ធធនាគារអនឡាញ អូរៀនថល និងសិទ្ធិផ្នែកច្បាប់ និងសិទ្ធិទទួលផល និងផលប្រយោជន៍លក្ខណៈណាក៏ដោយដែលទាក់ទងនឹងសិទ្ធិទាំងនេះដែលបានផ្តល់នៅក្រោមច្បាប់នៃប្រទេសកម្ពុជា និងប្រទេសទាំងអស់ក្នុងពិភពលោកសម្រាប់រយៈពេលពេញរបស់សិទ្ធិទាំងនេះ រួមជាមួយនឹងការបន្តជាថ្មី និងការបន្តសិទ្ធិទាំងនេះ។

9.2 គ្មានអ្វីនៅទីនេះត្រូវចាត់ទុកថាផ្តល់អាជ្ញាប័ណ្ណច្បាស់លាស់ ឬដោយប្រយោលណាមួយ (ឬសិទ្ធិផ្សេងទៀត) ដល់អ្នកក្នុងការប្រើប្រាស់ ផលិតឡើងវិញ ចម្លង ឬដោះស្រាយជាមួយកម្មសិទ្ធិបញ្ញា ឬកម្មសិទ្ធិបញ្ញាណាមួយ ឬច្រើនដែលមានកំណត់ក្នុងប្រការ 9.1 សេវាធនាគារអនឡាញ ORB និង សិទ្ធិ ដែលផ្តល់ឱ្យអ្នកនៅក្រោមលក្ខខណ្ឌទាំងនេះ ត្រូវបានផ្តល់ជូនអ្នកយ៉ាងតឹងរ៉ឹងសម្រាប់ការចូលប្រើ និង/ឬប្រើប្រាស់ផ្ទាល់ខ្លួនរបស់អ្នក។ សិទ្ធិ ORB Mobile Back ណាមួយដែលមិនត្រូវបានផ្តល់ឱ្យយ៉ាងច្បាស់នៅក្រោមលក្ខខណ្ឌទាំងនេះត្រូវបានរក្សាទាំងស្រុង និងផ្តាច់មុខសម្រាប់ និងដោយធនាគារ អូរៀនថល។

9.3 ដោយខ្លួនឯង ឬតាមរយៈភាគីទីបីណាមួយ អ្នកមិនត្រូវប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តអំពើរំលោភបំពានណាមួយ រួមទាំង ប៉ុន្តែមិនកំណត់ចំពោះការបង្កើតក្របខណ្ឌ តំណភ្ជាប់ដែលគ្មានការអនុញ្ញាត ការផ្ញើសារឥតបានការ និង/ឬការបំផ្លិចបំផ្លាញប្រព័ន្ធណាមួយដែលជាកម្មសិទ្ធិរបស់ធនាគារ អូរៀនថល ឡើយ។

9.4 ពីពេលមួយទៅពេលមួយ ធនាគារ អូរៀនថល អាចចេញសេចក្តីណែនាំ ឬការណែនាំទាក់ទងនឹងការប្រើប្រាស់កម្មសិទ្ធិបញ្ញា និងសិទ្ធិកម្មសិទ្ធិណាមួយដែលជាកម្មសិទ្ធិរបស់ធនាគារ អូរៀនថល (ឬអ្នកទទួលសិទ្ធិរបស់ខ្លួន) ហើយអ្នកនឹងត្រូវអនុវត្តតាមសេចក្តីណែនាំ ឬការណែនាំទាំងអស់នោះភ្លាមៗ។

## 10. ការធានាអះអាង

10.1 អ្នកអះអាង និងធានាចំពោះធនាគារ អូរៀនថល ថាៈ

10.1.1 លក្ខខណ្ឌទាំងនេះត្រូវបានអនុញ្ញាតត្រឹមត្រូវ និងបង្កើតជាកាតព្វកិច្ចស្របច្បាប់ ត្រឹមត្រូវ និងចងកាតព្វកិច្ចចំពោះអ្នក។

10.1.2 អ្នក និងបុគ្គលណាម្នាក់ដែលដាក់ពាក្យសុំ (ក) ការប្រតិបត្តិ និងការអនុវត្តលក្ខខណ្ឌទាំងនេះ (ខ) ការចូលប្រើ និង/ឬ រក្សាទុកកម្មវិធី ORB Mobile និង (គ) ការចេញការណែនាំណាមួយ ក្នុងនាមអ្នកបានចាត់វិធានការសាជីវកម្មចាំបាច់ទាំងអស់ និង សកម្មភាពពាក់ព័ន្ធផ្សេងទៀតដែលតម្រូវដោយសមាសធាតុរបស់

អតិថិជនដើម្បីអនុញ្ញាតការប្រតិបត្តិ និងការអនុវត្តលក្ខខណ្ឌទាំងនេះ ការចូលប្រើ និង/ឬការប្រើប្រាស់ធនាគារ អូរៀនថល និងការចេញសេចក្តីណែនាំក្នុងនាមអតិថិជន និង

10.1.3 ការប្រតិបត្តិ និងការអនុវត្តលក្ខខណ្ឌទាំងនេះ ការចូលប្រើ និង/ឬការប្រើប្រាស់កម្មវិធី ORB Mobile និងការចេញការណែនាំនឹងមិនលើសពីសិទ្ធិអំណាចដែលផ្តល់ឱ្យអ្នក ឬបុគ្គលដែលធ្វើសកម្មភាពជំនួសអ្នក ឬបំពានលើបទប្បញ្ញត្តិណាមួយរបស់៖

10.1.3.1. ច្បាប់ បទប្បញ្ញត្តិ ឬបទបញ្ជា សេចក្តីជូនដំណឹង គោលការណ៍ណែនាំ ឬក្រឹត្យរបស់អាជ្ញា-ធររដ្ឋាភិបាល ទីភ្នាក់ងារ ឬតុលាការណាមួយដែលអ្នកត្រូវអនុលោមតាម។

10.1.3.2. សម្រាប់អតិថិជនសាជីវកម្ម អនុស្សរណៈរបស់អ្នក និងលក្ខន្តិកៈក្រុមហ៊ុន ឬឯកសារដែលមានធាតុផ្សំផ្សេងទៀត។

10.2 អ្នកអះអាង និងធានាដល់ធនាគារ អូរៀនថល ថាមុនពេលចេញជីវមាត្រដល់អ្នកប្រើប្រាស់ណាមួយ អ្នកប្រើប្រាស់បែបនេះត្រូវបានផ្តល់ព័ត៌មាន និងណែនាំពីមុនអំពីប្រតិបត្តិការរបស់សេវាធនាគារ អនឡាញ ORBតួនាទីរបស់ជីវមាត្រៀងៗខ្លួនក្នុងក្របខណ្ឌសេវាធនាគារអនឡាញ ORB របៀបដាក់ការណែនាំ និងវិធានការសុវត្ថិភាពចាំបាច់នានាដើម្បីការពារជីវមាត្របុគ្គលរៀងៗខ្លួន។

10.3 អ្នកនឹងត្រូវបានចាត់ទុកថាអះអាង និងធានាដល់ធនាគារ អូរៀនថល នៅកាលបរិច្ឆេទនៃការបន្តឡើងវិញនីមួយៗនូវលក្ខខណ្ឌទាំងនេះ និង/ឬនៅកាលបរិច្ឆេទការដាក់ពាក្យសុំសេវាកម្មបន្ថែមរបស់អ្នកក្នុងសេវាធនាគារអនឡាញ ORB ដែលការអះអាង និងការធានាដែលមានក្នុងប្រការ 10.1 និង 10.2 ខាងលើនៅតែពិត និងត្រឹមត្រូវក្នុងគ្រប់ទិដ្ឋភាព ដូចបានធ្វើឡើងនៅកាលបរិច្ឆេទនោះ។ ប្រសិនបើការអះអាង ឬការធានា ឬរបាយការណ៍ណាមួយដែលមាននៅក្នុងនេះបង្ហាញថាបង្កការភាន់ច្រឡំ ឬមិនត្រឹមត្រូវ នោះអះអាង ឬការធានាត្រូវបានចាត់ទុកថាត្រូវបានធ្វើឡើងដោយមានការយល់ព្រម ឬការអនុញ្ញាតពី ឬដោយសារការធ្វេសប្រហែសពីផ្នែករបស់អ្នក ឬមន្ត្រី ឬបុគ្គលិករបស់អ្នកដែលសន្មតថាធ្វើសកម្មភាពជំនួសអ្នក។

10.4 លើកលែងតែមានចែងជាក់លាក់នៅទីនេះ ធនាគារ អូរៀនថល មិនអះអាង ឬធានាទាក់ទងនឹង៖

10.4.1 សេវាធនាគារអនឡាញ ORB និង/ឬជីវមាត្រា ថាតើវាទាក់ទងនឹងភាពអាចមាន សេវាធនាគារអនឡាញ ORB សម្រាប់បុគ្គល សុវត្ថិភាពរបស់ការណែនាំដែលបានដាក់ជូននោះ ការចូលប្រើដោយគ្មានការរំខានតាមរយៈគេហទំព័រសេវាធនាគារតាមអ៊ីនធឺណិត និង/ឬ សេវាកម្មវិធីធនាគារតាមទូរស័ព្ទនៅទីនោះ ការទទួលយក ឬសុពលភាពព័ត៌មានកំណត់អត្តសញ្ញាណ ឬការធានាដែលបង្កប់ន័យផ្សេងទៀត រួមទាំងភាពអាចធ្វើជំនួញបាន និងភាពស័ក្តិសមសម្រាប់គោលបំណងជាក់លាក់ណាមួយ។

10.4.2 រូបិយប័ណ្ណ ភាពត្រឹមត្រូវ ភាពអាចមាន ឬការផ្តល់ព័ត៌មាន ឬមាតិកាដែលមិនមានការរំខានដែលធ្វើឡើងជាផ្នែកនៃសេវាធនាគារតាមទូរស័ព្ទORB រួមទាំងប៉ុន្តែមិនកំណត់ចំពោះអត្រាប្តូរប្រាក់ អត្រាទីផ្សារប្តូរប្រាក់ ការអត្ថាធិប្បាយទីផ្សារ និងសេវាកម្មផ្សេងទៀតដូចដែលធនាគារអាចបន្ថែម លុប ឬកែប្រែពីពេលមួយទៅពេលមួយ និង

10.4.3 ថាតើសំណើ និងការណែនាំរបស់អ្នកដែលធ្វើឡើងក្នុងសេវាធនាគារតាមទូរស័ព្ទ ORB នឹងត្រូវធនាគារ អូ-រៀនថល បានផ្តល់ ឬលក្ខខណ្ឌដែលផ្តល់ការអនុម័តណាមួយ។

10.5 សេវាធនាគារតាមទូរស័ព្ទ ORB ត្រូវបានផ្តល់ជូនតាមមូលដ្ឋាន 'តាមមាន' និង 'តាមដែលអាចមាន' ដោយមិនមានធានាប្រភេទណាមួយ ទាំងបញ្ជាក់ច្បាស់ ឬប្រយោល តាមច្បាប់ ឬផ្សេងពីនេះទៀតឡើយ ។

## 11. ការទទួលខុសត្រូវ និងសំណងរបស់អតិថិជន

11.1 ដោយមិនប៉ះពាល់ចំពោះ និងបន្ថែមលើសិទ្ធិ និងដំណោះស្រាយរបស់ធនាគារ អូរៀនថល នៅក្នុងលក្ខខណ្ឌស្តង់ដាររបស់ខ្លួនក្នុងការយកមកវិញនូវការបាត់បង់ ឬការខូចខាតដែលកើតឡើងក្រោមគណនី និង/ឬគណនីផ្សេងៗពីម្ចាស់គណនីទាំងនោះ អ្នកត្រូវតែទទួលខុសត្រូវចំពោះធនាគារ អូរៀនថល ចំពោះការខាតបង់ ឬការខូចខាតណាមួយ មិនថាដោយផ្ទាល់ ឬដោយប្រយោលដែលជាគំរូ ជាផលវិបាក ដោយចៃដន្យ ដោយការដាក់ទណ្ឌកម្ម ការខាតបង់ ឬការខូចខាតពិសេស ឬការបាត់បង់ប្រាក់ចំណូល ប្រាក់ចំណេញ ឬកេរ្តិ៍ឈ្មោះ (រួមទាំងភាគីទីបីណាមួយ) ដែលកើតឡើងក្រោមគណនី គណនីផ្សេងៗ ឬផ្សេងពីនេះដែលធនាគារ អូរៀនថល ទទួលរងពី ឬពាក់ព័ន្ធនឹងការណែនាំណាមួយ (ឬស៊េរី ឬផ្នែកណាមួយនៃការណែនាំ) បានទទួល ឬធ្វើឡើងតាមសេវាធនាគារតាមទូរស័ព្ទ ORB របស់អ្នក ឬការរំលោភបំពានណាមួយរបស់អ្នកចំពោះលក្ខខណ្ឌទាំងនេះ។

11.2 ដោយមិនប៉ះពាល់ចំពោះជម្រើសរបស់អតិថិជនក្នុងការដោនឡូត និងដំឡើងកម្មវិធី ORB Mobile នោះ អ្នកត្រូវតែទទួលខុសត្រូវ ហើយត្រូវសងសំណងទាំងស្រុង បង្ការ ការពារ និងធ្វើឱ្យធនាគារ អូរៀនថល ក្រុមហ៊ុនដែលពាក់ព័ន្ធ មន្ត្រី បុគ្គលិក អ្នកមៅការបន្ត និង/ឬភ្នាក់ងាររបស់ខ្លួន (ជារួម 'អ្នកទទួលសំណង') មិនឱ្យទទួលរងនិងទូទាត់សងពួកគេសម្រាប់ការទាមទារ បណ្តឹង សកម្មភាព ដំណើរការនីតិវិធី ការខាតបង់ ការខូចខាត បន្ទុក ការចំណាយ (រួមទាំងចំណាយផ្លូវច្បាប់ និងការចំណាយមេធាវី និងអតិថិជន) និងបំណុលផ្សេងទៀតដែលបានធ្វើឡើង និង/ ឬបង្កើតឡើង ទទួលរង និង/ឬកើតឡើងចំពោះអ្នកទទួលសំណងណាមួយ ឬទាំងអស់ ទោះជាបង្កឡើងដោយផ្ទាល់ ឬដោយប្រយោលពី៖

11.2.1 សកម្មភាពក្លែងបន្លំ ឆ្វេសប្រហែស ភាន់ច្រឡំ និង/ឬដោយចេតនា កំហុស និង/ឬ ការធ្វេសប្រហែស របស់អ្នក។

11.2.2 ការមិនប្រតិបត្តិតាម ឬបំពានលើកាតព្វកិច្ច លក្ខខណ្ឌ កិច្ចព្រមព្រៀង កិច្ចសន្យា និង/ឬការធានាណាមួយខាងក្រោមនេះ។

11.2.3 ការផ្តល់នូវព័ត៌មាននិង/ឬការណែនាំមិនត្រឹមត្រូវ មិនពេញលេញ បំភាន់ មានកំហុស និង/ឬក្លែងបន្លំរបស់អ្នកមកធនាគារ អូរៀនថល។

11.2.4 ការខូច ឬការឆ្លងមេរោគចំពោះ ឬផ្សេងពីនេះ ឬការរំខានដល់ ឬការបំបែកនូវកម្មវិធី ORB Mobile និង/ឬប្រព័ន្ធរបស់ភាគីទីបី ដោយផ្ទាល់ ឬដោយប្រយោលដោយសារអ្នក។

11.2.5 ការអនុវត្តនូវសិទ្ធិរបស់ធនាគារ អូរៀនថល ដែលមាននៅទីនេះ គឺបណ្តាលមកពីការបំពាននូវកាតព្វ-កិច្ចណាមួយរបស់អ្នកនៅក្នុងលក្ខខណ្ឌទាំងនេះ។

11.2.6 ការមិនអនុវត្តយ៉ាងតឹងរ៉ឹងនូវកាតព្វកិច្ចសន្តិសុខរបស់អ្នកនៅទីនេះ និង/ឬសកម្មភាពបន្តបន្ទាប់ ឬការឆ្វេសប្រហែសរបស់បុគ្គលណាម្នាក់ ដែលប្រើប្រាស់ព័ត៌មានកំណត់អត្ត-សញ្ញាណដែលបណ្តាលមកពី ការមិនអនុវត្តកាតព្វកិច្ចសន្តិសុខដែលបានរៀបរាប់ខាងលើ។

11.2.7 បណ្តឹងណាមួយដែលកើតឡើងពីការរំលោភបំពានរបស់អ្នក ឬការប្រើប្រាស់មិនត្រឹមត្រូវនូវពាណិជ្ជសញ្ញាសិទ្ធិថតចម្លង ឬសិទ្ធិកម្មសិទ្ធិបញ្ញាផ្សេងទៀតរបស់ភាគីទីបី។

11.2.8 ការប្រើប្រាស់កម្មវិធី ORB Mobile សម្រាប់គោលបំណងមិនស្របច្បាប់ ឬខុសច្បាប់របស់អ្នក។

11.2.9 ការអះអាងទាមទារ ការទាមទារ បណ្តឹង ឬដំណើរការនីតិវិធីរបស់ភាគីទីបីណាមួយដែលបានធ្វើឡើងចំពោះធនាគារ អូរៀនថល ជាលទ្ធផលការណែនាំណាមួយដែលអ្នកបានធ្វើឡើង និងត្រូវបានធនាគារអនុ-វត្តឱ្យមានប្រសិទ្ធភាព និង

11.2.10 បណ្តឹងផ្លូវច្បាប់ វិវាទ បណ្តឹង និងការខ្វែងគំនិតគ្នាទាក់ទងនឹងអ្នក មិនថាជាអ្នកផ្ញើ ឬអ្នកទទួលផលអនុលោមតាមការទូទាត់ ឬប្រតិបត្តិការដែលបានទទួល

## 12. ការលើកលែងការទទួលខុសត្រូវ

12.1 នៅករណីណាមួយក៏ដោយ ធនាគារ អូរៀនថល នឹងមិនទទួលខុសត្រូវចំពោះអ្នក ឬភាគីទីបីណាមួយចំពោះការបាត់បង់ ឬការខូចខាតណាមួយឡើយ ទោះជាដោយផ្ទាល់ ឬដោយប្រយោល ជាគំរូ ជាផលវិបាកដោយចៃដន្យ ដោយការដាក់ទណ្ឌកម្ម ការខាតបង់ ឬការខូចខាតពិសេស ឬការបាត់បង់ប្រាក់ចំណូលប្រាក់ចំណេញ ឬកេរ្តិ៍ឈ្មោះ (រួមទាំងរបស់ភាគីទីបី) ទោះជានៅក្នុងកិច្ចសន្យា ការបំពាន (រួមទាំងការធ្វេសប្រហែស) ការបំពានកាតព្វកិច្ចតាមច្បាប់ ឬផ្សេងពីនេះ ដែលកើតឡើងពី ឬពាក់ព័ន្ធនឹងបទប្បញ្ញត្តិរបស់ធនាគារ អូរៀនថល ឬការចូលប្រើរបស់អ្នក និង/ឬការប្រើប្រាស់ សេវាធនាគារតាមទូរស័ព្ទ ORB Mobile ឬសម្ភារៈ ធនធាន ឬ សេវាកម្មផ្សេងៗដែលបានផ្តល់នៅក្រោមលក្ខខណ្ឌទាំងនេះ ទោះបីជាធនាគារ អូរៀន

ថល ត្រូវបានណែនាំអំពីលទ្ធភាពនៃការបាត់បង់ ឬការខូចខាតនេះជាមុន ហើយការខូចខាតទាំងអស់នេះត្រូវបានដកចេញយ៉ាងច្បាស់លាស់។ ដោយមិនកំណត់លក្ខណៈទូទៅនៃការរៀបរាប់ខាងលើ ធនាគារ អូ-រៀនថល នឹងមិនទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាតណាមួយដែលកើតឡើងពីព្រឹត្តិការណ៍ខាងក្រោម៖

12.1.1. ភាពមិនមានសុពលភាព ភាពមិនមានសុក្រិតភាព ភាពមិនត្រឹមត្រូវ ឬភាពមិនពេញលេញនៃការណែនាំ ឬព័ត៌មាន ORB Mobile Back ណាមួយ (ថាតើមានការអនុញ្ញាត ឬអត់)។

12.1.2. ការពន្យារពេល ឬការមិនអនុវត្តការណែនាំ ទិន្នន័យ ឬឯកសារសម្រាប់ហេតុផលណាមួយក៏ដោយ។

12.1.3. ការពន្យារពេល ឬការមិនអនុវត្តការណែនាំណាមួយដើម្បីបញ្ឈប់ដំណើរការប្រតិបត្តិការ ឬផ្សេងពីនេះដើម្បីបញ្ឈប់ការទូទាត់ ឬការផ្ទេរប្រាក់ណាមួយ។

12.1.4. ការខកខាន ឬការពន្យារពេលរបស់អ្នកក្នុងការចូលប្រើ និង/ឬប្រើប្រាស់ផ្នែកណាមួយនៃសេវាធនាគារតាមទូរស័ព្ទ ORB សម្រាប់ហេតុផលណាមួយក៏ដោយ រួមទាំងនៅពេលដែលការខកខាន ឬការពន្យារពេលនេះបណ្តាលមកពីភាគីទីបី។

12.1.5. ការខូចប្រព័ន្ធ កំហុសក្នុងដំណើរការ ការខូចសូហ្វវែរ កំហុសក្នុងប្រតិបត្តិការ ការខូចហាដវែរ សមត្ថភាពមិនគ្រប់គ្រាន់ ភាពងាយរងគ្រោះរបស់បណ្តាញ ភាពទន់ខ្សោយក្នុងការគ្រប់គ្រង កង្វះសុវត្ថិភាព ការវាយប្រហារប្រព័ន្ធ ឧបទ្ទវហេតុការលួចចូលប្រើ សកម្មភាពក្លែងបន្លំ និងសមត្ថភាពស្តារប្រតិបត្តិការឡើងវិញមិនគ្រប់គ្រាន់។

12.1.6. ប្រតិបត្តិការណាមួយត្រូវបានធនាគារ អូរៀនថល ដំណើរការយ៉ាងត្រឹមត្រូវ ទោះបីជាធនាគារ អូរៀនថល ទទួលសំណើរបស់អ្នកក្នុងការធ្វើឱ្យអស់សុពលភាព និង/ឬលុបចោលប្រតិបត្តិការបែបនេះ ឬការជូនដំណឹងរបស់អ្នកថា ការណែនាំទាក់ទងនឹងប្រតិបត្តិការគឺមិនមានការអនុញ្ញាត។

12.1.7. ទង្វើ ឬការធ្វេសប្រហែសរបស់ធនាគារ អូរៀនថល ទាំងក្នុងការឆ្លើយតបទៅនឹងការមិនអនុលោមតាមច្បាប់របស់អ្នក ឬការរំលោភបំពានលើកាតព្វកិច្ច លក្ខខណ្ឌ កិច្ចព្រមព្រៀង ការសន្យា និង/ឬការធានាណាមួយរបស់អ្នកនៅទីនេះ ឬដោយពឹងផ្អែកលើការផ្តល់ព័ត៌មានមិនត្រឹមត្រូវ ភាន់ច្រឡំ មានកំហុស និង/ឬព័ត៌មាន និង/ឬការណែនាំក្លែងបន្លំ។

12.1.8. ជីវមាត្រណាមួយ ឬទាំងអស់ដំណើរការខុសប្រក្រតី។

12.1.9. នៅពេលដែលចាំបាច់ត្រូវរួមបញ្ចូលជាមួយអ្នកផ្តល់ប្រព័ន្ធភាគីទីបី សម្រាប់ការបាត់បង់ ឬការខូចខាតទាក់ទងនឹងកំហុស ឬការបំពាននៃការរួមបញ្ចូលប្រព័ន្ធភាគីទីបីណាមួយ ដូចដែលអ្នកអ្នកប្រើប្រាស់ រួមបញ្ចូលប៉ុន្តែមិនកំណត់ចំពោះកំហុសណាមួយ ឬការបំពាននៅលើផ្នែករបស់ភាគីទីបី ឬកំហុស ឬការបំពានក្នុងការតភ្ជាប់ ឬសុក្រិតភាព ភាពពេញលេញ ឬភាពត្រឹមត្រូវនៃទិន្នន័យ។ អ្នកយល់ព្រមថាក្នុងករណីដែល

សេវាកម្មគ្រប់គ្រងសាច់ប្រាក់មិនអាចអនុវត្តបាន ឬអនុវត្តបានដោយសារកត្តាដែលបានរៀបរាប់ខាងលើ ធនាគារ អូរៀនថល មិនមានកាតព្វកិច្ចណាមួយក្នុងការកែតម្រូវ ឬអនុវត្ត ឬផ្តល់របៀបជំនួស ឬបណ្តាញទាក់ទងនឹងសេវាគ្រប់គ្រងសាច់ប្រាក់ដែលបានរៀបរាប់ខាងលើនោះទេ។ ធនាគារ អូរៀនថល មិនមានកាតព្វកិច្ចក្នុងការធានាថាការរួមបញ្ចូលប្រព័ន្ធភាគីទីបីណាមួយគឺគ្មានមេរោគ ឬការខូចខាតនោះទេ។

## 13. ការបង្ហាញព័ត៌មាន

13.1 ទោះបីជាកាតព្វកិច្ចរបស់ធនាគារ អូរៀនថល ក្នុងការរក្សាការសម្ងាត់ចំពោះអតិថិជនរបស់យើង និងតាមវិសាលភាពដែលអនុញ្ញាតដោយច្បាប់ក៏ដោយ តាមរយៈការស្នើសុំ និង/ឬបន្តប្រើប្រាស់សេវាធនាគារតាមទូរស័ព្ទ ORB អ្នកយល់ព្រមថា ធនាគារ អូរៀនថល អាចប្រើប្រាស់ និងបង្ហាញព័ត៌មានរបស់អ្នកទៅកាន់ស្ថាប័នគ្រប់គ្រង ភ្នាក់ងាររដ្ឋាភិបាល ស្ថាប័-នអនុវត្តច្បាប់ និងតុលាការក្នុងប្រទេស និងធនាគារជាតិនៃកម្ពុជា ឬភាគីណាមួយដែលច្បាប់តម្រូវ។

13.2 តាមវិសាលភាពដែលច្បាប់អនុញ្ញាត អ្នកអាចចូលប្រើ និងស្នើសុំការកែតម្រូវព័ត៌មានរបស់អ្នកបានគ្រប់ពេល ដោយស្នើសុំកែប្រែនៅតាមសាខាធនាគារ អូរៀនថល ណាមួយ។

## 14. ការដោះស្រាយវិវាទ និងច្បាប់គ្រប់គ្រង

ប្រសិនបើអ្នកមានចម្ងល់ដែលត្រូវការជំនួយបន្ថែមអំពីសេវាធនាគារតាមអ៊ីនធឺណិត និងសេវាធនាគារតាមទូរស័ព្ទ អ្នកអាចទូរស័ព្ទទៅលេខ (855) 23 932 288 ឬផ្ញើអ៊ីមែលទៅ customerservice@orientalbank.com.kh។

## 15. ការបដិសេធនូវសេវាកម្ម

15.1 ទោះបីជាមានសិទ្ធិណាមួយដែលមានចែងនៅក្នុងលក្ខខណ្ឌទាំងនេះក៏ដោយ ក្នុងករណីដែលអ្នកមើលទៅដូចជាបុគ្គលដែលត្រូវហាមឃាត់នោះ យើងអាចបដិសេធភ្លាមៗក្នុងដំណើរការ ឬបញ្ចប់ប្រតិបត្តិការ ឬសកម្មភាពណាមួយរបស់អ្នក។ ផ្អាកការផ្តល់ផលិតផល ឬសេវាកម្មដល់អ្នក បដិសេធមិនអនុញ្ញាត ឬសម្របសម្រួលទ្រព្យសម្បត្តិណាមួយរបស់អ្នកដែលយើងកាន់កាប់ដើម្បីប្រើប្រាស់ ឬដោះស្រាយនោះ បដិសេធមិនធ្វើផ្តល់ទ្រព្យសកម្មណាមួយដល់អ្នក សម្រាប់ឱ្យអ្នកឱ្យទៅបុគ្គលឬអង្គភាពផ្សេងណាមួយដែលត្រូវហាមឃាត់នោះ ឬក៏បញ្ចប់ការរៀបចំទាំងនេះជាមួយអ្នក។

15.2 យើងនឹងមិនទទួលខុសត្រូវចំពោះអ្នក ឬចាត់វិធានការណាមួយ ឬទាំងអស់ដែលមានចែងក្នុងប្រការ 16.1 ឡើយ ប្រសិនបើយើងអនុវត្តសិទ្ធិរបស់យើងនៅក្នុងប្រការនេះ អ្នកត្រូវតែបង់ការខាតបង់ បន្ទុក ឬការ

ចំណាយនានាដែលយើងទទួលរងទាក់ទងនឹងសកម្មភាពណាមួយដែលបានធ្វើឡើងនៅក្នុងប្រការនេះ រួមទាំងការកែប្រែការប្រាក់ និង/ឬការចំណាយរដ្ឋបាលនៅក្នុងលក្ខខណ្ឌទាំងនេះ។

## 16. ការព្យួរ និងបញ្ចប់សេវាកម្ម

16.1 អ្នកអាចបញ្ឈប់ការប្រើប្រាស់សេវាធនាគារអនឡាញ ORB បាននៅពេលណាមួយ ដោយជូនដំណឹងយើងខ្ញុំជាលាយលក្ខណ៍អក្សរ ឬតាមទូរស័ព្ទ។ អ្នកនឹងនៅតែទទួលខុសត្រូវចំពោះប្រតិបត្តិការណាមួយដែលបានធ្វើឡើងនៅលើគណនីរបស់អ្នកដោយប្រើប្រាស់សេវាធនាគារ អនឡាញ ORB រហូតដល់ពេលដែល ការបញ្ឈប់ការប្រើប្រាស់នោះមានប្រសិទ្ធភាព។

16.2 ទោះបីជាមានបទប្បញ្ញត្តិផ្សេងទៀតនៅក្នុងលក្ខខណ្ឌនេះក៏ដោយ នៅគ្រប់ពេលវេលា ដោយមានឬគ្មានការជូនដំណឹង និងដោយមិនចាំបាច់ផ្តល់ហេតុផលណាមួយដល់អ្នក យើងអាចបញ្ឈប់ជាបន្ទាន់ ផ្អាក ឬបិទ សេវាធនាគារ អនឡាញ ORB (ឬផ្នែកណាមួយនៃសេវាកម្ម) ឬសិទ្ធិរបស់អ្នកក្នុងការចូលប្រើ និងប្រើប្រាស់សេវាធនាគារអនឡាញ អូរៀនថល (ឬផ្នែកណាមួយនៃសេវាកម្ម) ដោយគ្មានលក្ខខណ្ឌ ឬផ្សេងពីនេះតាមឆន្ទានុសិទ្ធិឯកតោភាគី និងដាច់ខាតរបស់យើង។ ធនាគារ អូរៀនថល ក៏អាចដាក់លក្ខខណ្ឌលើការផ្អាក រួមទាំងរយៈពេលនៃការផ្អាក និងការដាក់ឱ្យប្រើប្រាស់ឡើងវិញនូវសេវាកម្ម និងលក្ខខណ្ឌតម្រូវមុនពេលការដាក់ឱ្យប្រើប្រាស់ឡើងវិញណាមួយ។

16.3 នៅពេលការផ្អាក ឬការបញ្ចប់សេវាកម្មទាំងដោយធនាគារ ឬដោយអ្នកដោយការជូនដំណឹងទៅធនាគារជាលាយលក្ខណ៍អក្សរ ឬតាមទូរស័ព្ទ យើងមិនត្រូវមានកាតព្វកិច្ចធ្វើទៅតាមការណែនាំណាមួយរបស់អ្នកទេ ទោះបីជាបានទទួលមុន ឬក្រោយកាលបរិច្ឆេទនៃការផ្អាក ឬបញ្ចប់សេវាកម្មជាធរមាន ហើយដែលយើងមិនទាន់បានអនុវត្តរួចរាល់តាមឆន្ទានុសិទ្ធិឯកតោភាគី និងដាច់ខាតរបស់យើង។ ប្រសិនបើមានបញ្ហា ឬសកម្មភាពនៅសេសសល់ណាមួយដែលយើងតម្រូវឱ្យអ្នកអនុវត្តតាម អ្នកត្រូវតែចាត់វិធានការចាំបាច់ទាំងអស់ក្នុងការអនុវត្តការបញ្ចប់ ឬបញ្ចប់សកម្មភាពទាំងអស់នៅក្នុង ឬអនុលោមតាមសេវាកម្ម ឬប្រព័ន្ធ។ រាល់សិទ្ធិ និងអាជ្ញាបណ្ណដែលផ្តល់ឱ្យអ្នកនៅក្នុងលក្ខខណ្ឌនេះ ត្រូវតែបញ្ឈប់ជាបន្ទាន់។ ការបញ្ចប់ ឬការផ្អាកនូវសេវាកម្មដោយយើងខ្ញុំនឹងមិនផ្តល់សិទ្ធិឱ្យអ្នកទេ ហើយអ្នកលះបង់សិទ្ធិទាំងអស់ចំពោះការទាមទារ ឬសំណងណាមួយចំពោះយើងសម្រាប់ការបាត់បង់ ឬការខូចខាតទាំងអស់ដែលអ្នកទទួលរង ឬកើតឡើងចំពោះអ្នក ដែលជាលទ្ធផលដោយផ្ទាល់ ឬដោយប្រយោលនៃសកម្មភាពនៃការបញ្ចប់ ឬ ការព្យួរសេវាកម្មនេះ។

## 17. គោលការណ៍ឯកជនភាព

ដោយការចុះឈ្មោះដោយជោគជ័យជាអ្នកប្រើប្រាស់សេវាធនាគារអនឡាញ ORB និងការចូលប្រើសេវាកម្ម អ្នកទទួលស្គាល់ថាអ្នកបានអានគោលការណ៍ឯកជនភាពរបស់យើង ហើយយល់ព្រមឱ្យធនាគារ អូរៀន

ចល ដំណើរការព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកតាមរបៀបដែលបានពិពណ៌នា រួមទាំងការបង្ហាញព័ត៌មានចាំបាច់ដល់ភាគីទីបីដែលពាក់ព័ន្ធតាមតម្រូវការ។

## ORIENTAL ONLINE BANKING TERMS AND CONDITIONS

Oriental Internet Banking and/or Mobile Banking ("Online Banking")

These terms and conditions constitute an agreement between Oriental Bank and our customer/users relating to the use to Oriental Internet Banking and/or Mobile Banking ("Online Banking") which enables customers/users to electronically access and use their accounts and other banking facilities, Products and services as made available in Online Banking by Oriental Bank PLC ("ORB").

Please also note that any other written terms and conditions which relate to your ORB accounts services will continue to apply. To the extent such other terms and conditions are inconsistent with these terms and conditions, these terms and conditions shall prevail (unless such other terms and conditions are expressed to apply instead of these terms and conditions).

Any inconsistency of languages, the English language shall prevail to the extent of this inconsistency.

### 1. Definitions and Interpretation

In these Terms and Conditions where the context so admits, the following expressions shall have the meanings designated as follows unless otherwise stated:

**Account (s):** Refer to one or more of your accounts held with ORB which includes Savings Account, Current Account, Fixed Deposit Account or Loan account in both KHR and USD currencies as may be created from time to time at ORB branches.

**CIF No:** A unique customer identification number in ORB's system that you receive during your first account opening with ORB.

**Content:** Means and includes any information, images, links, sounds, graphics, video, software or other materials, including quotes, news and research data, made available through ORB Online Banking.

**Fixed Deposit E-Certificate:** An electronic document of your Fixed Deposit Account details as an image opened via ORB Mobile App.

**Biometric:** A fingerprint, facial data and any other means by which a mobile device manufacturer allows Users to authenticate their identity for the purposes of unlocking their mobile device and access to specific applications.

